ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ៥៧/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នឹងអញ្ជើញចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៦ នៅទីក្រុងគីហ្គាលី សាធារណរដ្ឋរ៉ាន់ដា

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងអញ្ជើញធ្វើដំណើរទៅចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី (សន្និសីទ CMF) លើកទី៤៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៩-២០ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីក្រុងគីហ្គាលី សាធារណរដ្ឋរ៉ាន់ដា តាមការអញ្ជើញរបស់ ឯកឧត្តម Jean-Noël BARROT រដ្ឋមន្ត្រីក្រសួងអឺរ៉ុប និងការបរទេស នៃសាធារណរដ្ឋបារាំង និងឯកឧត្តម Olivier J.P. NDUHUNGIREHE រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃសាធារណរដ្ឋរ៉ាន់ដា។

ក្រោមមូលបទ *«៣០ ឆ្នាំបន្ទាប់ពីសន្និសីទទីក្រុងប៉េកាំង៖ ការរួមចំណែករបស់ស្ត្រីនៅក្នុងបណ្តាប្រទេសហ្វ្រង់កូហ្វូន»* សន្និសីទ CMF លើកទី៤៦ គឺជាឱកាសមួយសម្រាប់រដ្ឋមន្ត្រីនៃប្រទេសសមាជិកអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) និងអ្នកចូលរួមទាំងអស់ អាចផ្លាស់ប្តូរយោបល់អំពីបញ្ហាប្រឈមទាក់ទងនឹងការវិវត្តនៃស្ថានភាពស្ត្រីនៅក្នុងប្រទេសហ្វ្រង់កូហ្វូន ព្រមទាំងគូសបញ្ជាក់ឡើងវិញនូវការប្តេជ្ញានានា ដែលត្រូវបានអនុម័តអំឡុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី១៩ ឆ្នាំ២០២៤។

ក្នុងនាមកម្ពុជាជាប្រទេសម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ឆ្នាំ២០២៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** នឹងជម្រាបជូនសន្និសីទនូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការងារត្រៀមរៀបចំកិច្ចប្រជុំកំពូលនេះ។

ក្នុងឱកាសអញ្ជើញចូលរួមសន្និសីទ CMF លើកទី៤៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** នឹងជួបពិភាក្សាទ្វេភាគីជាមួយលោកជំទាវអគ្គលេខាធិការអង្គការ OIF ព្រមទាំងរដ្ឋមន្ត្រីមួយចំនួនទៀតនៃបណ្តាប្រទេសសមាជិក OIF ដើម្បីពង្រឹង និងជំរុញទំនាក់ទំនងទ្វេភាគីឱ្យកាន់តែស៊ីជម្រៅថែមទៀត។

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ មុនសន្និសីទ CMF លើកទី៤៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** នឹងអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋរ៉ាន់ដា តបតាមការអញ្ជើញរបស់ ឯកឧត្តម Olivier J.P. NDUHUNGIREHE រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃសាធារណរដ្ឋរ៉ាន់ដា។ អំឡុងពេលនៃទស្សនកិច្ច ភាគីទាំងពីរនឹងចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នារវាងក្រសួងទាំងពីរ ដែលជាជំហានដ៏សំខាន់ឆ្ពោះទៅពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋរ៉ាន់ដា។

ថ្ងៃសៅរ៍ ១០រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh